**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

សុន្ទរកថា
ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ក្នុងកិច្ចប្រជុំស្តីពីការពង្រឹងការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ
នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ

សៀមរាប ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

- ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី
- ឯកឧត្តម សង់ វីហា អភិបាលរងខេត្តសៀមរាប
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសមាជិក សមាជិកា អង្គប្រជុំទាំងអស់

ថ្ងៃនេះ ខ្ញុំមានសេចក្តីរំភើបរីករាយជាអនេក ដែលបានចូលរួមជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំស្តីពីការពង្រឹងការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ នៅខេត្តសៀមរាប ដ៏ស្រស់ត្រកាលនេះ។ ជាច្រើនឆ្នាំកន្លងទៅនេះ កិច្ចប្រជុំបែបនេះត្រូវបានធ្វើឡើង នៅតាមកន្លែងជាច្រើន។ ប៉ុន្តែនៅឆ្នាំ២០១៦នេះ កិច្ចប្រជុំត្រូវបានរៀបចំនៅខេត្តសៀមរាបរបស់យើង។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។ ក្នុងនោះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាស្ថាប័នដឹកនាំ និងអនុវត្តការងារបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ត្រូវបានបង្កើតឡើង។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ

អេដស៍បាននិងកំពុងដឹកនាំសម្របសម្រួលជាលក្ខណៈពហុវិស័យ និងបានរួមចំណែកក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍រហូតបានទទួលជោគជ័យនាពេលនេះ។

ជាការពិតណាស់ ជោគជ័យទាំងឡាយដែលយើងទទួលបាននាពេលនេះ គឺពិតជាមាននូវការរួមចំណែកដែលមិនអាចខ្វះបាននូវការអនុវត្តសេចក្តីជូនដំណឹង លេខ ៦៦ស.ជ.ណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

កិច្ចប្រជុំរបស់យើងនៅពេលនេះ មានគោលបំណងផ្តោតជាសំខាន់លើការយល់ដឹងពីសកម្មភាពទាំងឡាយដែលទាក់ទងនឹងកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅតាមគ្រឹះស្ថានកំសាន្តសប្បាយនានា។ ជាមួយគ្នានេះ យើងក៏រួមគ្នាពិភាក្សាអំពីការលំបាកនានាដែលអាចកើតមានក្នុងការអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តសៀមរាប ជាពិសេសគឺការអនុវត្តគោលនយោបាយ ៧ចំណុចរបស់រាជរដ្ឋាភិបាល ដែលរួមមានការពង្រឹងនូវការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ។

តាមរយៈប្រធានបទដ៏មានសារៈសំខាន់ខាងលើនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមសម្តែងនូវការគាំទ្រ និងកោតសរសើរចំពោះគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងជាពិសេសម្ចាស់គ្រឹះស្ថានកម្សាន្តសប្បាយក្នុងខេត្តសៀមរាបទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងអន្តរាគមឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងរយៈកាលកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន និងទៅអនាគត។

ពិតមែនតែយើងកំពុងមានមោទនភាពចំពោះជោគជ័យក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់ពី ២% នៅឆ្នាំ១៩៩៨ មកនៅត្រឹម០,៦% នៅបច្ចុប្បន្ននេះក្តី ក៏យើងក៏នៅមានភាពប្រឈម និងកិច្ចការជាច្រើនទៀតដែលត្រូវតែរួមគ្នាធ្វើ និងដោះស្រាយជាបន្តទៀត។ ក្នុងនោះគឺការធ្វើឱ្យសម្រេចបាននូវគោលដៅ ៩០-៩០-៩០ នាឆ្នាំ២០២០ខាងមុខ និងឈានទៅលុបបំបាត់ការរីករាលដាលទាំងស្រុងនាឆ្នាំ២០២៥។ ដោយឡែក ខេត្តសៀមរាប គឺជាខេត្តមួយក្នុងចំណោមខេត្តពីរដែលត្រូវធ្វើឱ្យសម្រេចនូវការអនុវត្តគម្រោងសាកល្បងមុនគេ ចេញពីស្មារតីនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦កន្លងទៅនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីរាប់អាន*

ក្នុងឱកាសដ៏វិសេសវិសាលនៃកិច្ចប្រជុំនាពេលនេះ ខ្ញុំសូមធ្វើការចាប់អារម្មណ៍ និងជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) បន្ត និងពង្រឹងការអនុវត្តសេចក្តីជូនដំណឹងលេខ ៦៦.ស.ជ.ណ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យ១០០% នៅតាមគ្រឹះស្ថានបម្រើសេវាកម្សាន្តសប្បាយ ។

២) សូមម្ចាស់គ្រឹះស្ថានបម្រើសេវាកម្សាន្តសប្បាយទាំងអស់បន្តចូលរួមសហការ និងអនុវត្តន៍សេចក្តីជូនដំណឹងលេខ ៦៦.ស.ជ.ណ របស់រាជរដ្ឋាភិបាល ឱ្យមានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ជាពិសេសគឺការដាក់តាំង និងចែកចាយស្រោមអនាម័យ នៅក្នុងគ្រឹះស្ថានកម្សាន្តសប្បាយរបស់ខ្លួន។

៣) កំណត់ផែនទីអន្តរាគមន៍ទៅលើក្រុមប្រឈមមុខខ្ពស់ដូចជា អ្នកបម្រើការងារនៅតាមគ្រឹះស្ថានបម្រើសេវាកម្សាន្តសប្បាយ អ្នកប្រើប្រាស់គ្រឿងញៀន បុរសរួមភេទជាមួយបុរសជាដើម។ល។

មុននឹងបញ្ចប់ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប អង្គការ PSK ដែលបានសម្របសម្រួល និងរៀបចំកិច្ចប្រជុំថ្ងៃនេះ និង សូមថ្លែងអំណរគុណចំពោះការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាពេលនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកសមាជិកាកិច្ចប្រជុំទាំងមូល សូមមានសុខភាពល្អ និងសម្រេចបាននូវជោគជ័យគ្រប់ភារកិច្ច។

*សូមអរគុណ!*